ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន
និង សង្គ្រោះជនពិការដោយសារមីន

លេខ: ✓ / អន / អជម / ២០២៥

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការច្រានចោលចំពោះការលើកឡើងរបស់ក្រសួងការបរទេសថៃ លើករណីទាហានថៃបីនាក់រងគ្រោះថ្នាក់ដោយសារមីននៅក្នុងតំបន់ព្រំដែន

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) សូមបដិសេធ និងច្រានចោលទាំងស្រុង ចំពោះសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសថៃ ដែលចុះផ្សាយនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥ ដោយបានចោទប្រកាន់ថា កម្ពុជាបានដាក់មីនថ្មី។

កម្ពុជានៅតែរក្សាជំហរម៉ឺងម៉ាត់ គឺមិនមានការប្រើប្រាស់ ហើយនឹងមិនប្រើប្រាស់មីនថ្មីជាដាច់ខាត។ កម្ពុជា មានមោទកភាព ក្នុងនាមជារដ្ឋភាគីអនុសញ្ញាហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស ដែលកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩៩ ហើយកម្ពុជាត្រូវបានទទួលស្គាល់ជាអន្តរជាតិ ចំពោះសមិទ្ធផលនៃការបោសសម្អាតមីន និងមិនមានការប្រើប្រាស់មីនប្រឆាំងមនុស្សនោះឡើយ។ កម្ពុជា បានបោសសម្អាតមីនប្រឆាំងមនុស្សប្រមាណជាងមួយលានគ្រាប់ និងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រមាណជាងបីលានគ្រាប់ ដែលបានជួយសង្គ្រោះជីវិតមនុស្សជាច្រើន និងផ្តល់ដីសុវត្ថិភាពដល់សហគមន៍។

មកដល់ពេលនេះ មិនទាន់មានការស៊ើបអង្កេតផ្លូវការ និងមានតម្លាភាព ដើម្បីបញ្ជាក់ពីការពិតនៅឡើយពាក់ព័ន្ធនឹងបញ្ហានេះ ហេតុនេះ គ្រប់ភាគីពាក់ព័ន្ធគួរចៀសវាងការធ្វើសេចក្តីថ្លែងការណ៍ ជាសាធារណៈណាមួយ។ ការចោទប្រកាន់ដោយគ្មានការពិត នឹងប៉ះពាល់យ៉ាងខ្លាំងចំពោះស្មារតីបទឈប់បាញ់ និងបាត់ទំនុកចិត្តរវាងគ្នានិងគ្នា នៅក្នុងស្ថានភាពនេះ។

កម្ពុជាសង្ឃឹមថា ភាគីថៃនឹងគោរពបាននូវចំណុចដែលឯកភាពគ្នា ក្នុងកិច្ចប្រជុំវិសាមញ្ញគណៈកម្មាធិការព្រំដែនទូទៅកម្ពុជាថៃ (GBC) ជាពិសេសចំណុចទី២ ដែលបានចែងថា ភាគីទាំងពីរ មិនត្រូវចល័តកងទ័ពរបស់ខ្លួន រាប់បញ្ចូលទាំងការមិនដើរល្បាតហួសពីទីតាំងរបស់ខ្លួនដែលឈរជើងឡើយ។

យើងត្រៀមខ្លួនរួចជាស្រេច ដើម្បីផ្តល់កិច្ចសហការជាមួយភាគីថៃ សហគមន៍អាស៊ាន និងសហគមន៍មីនអន្តរជាតិ ដើម្បីប្រកាន់ខ្ជាប់នូវសន្តិភាព និងលើកកម្ពស់សុខសុវត្ថិភាព។

កម្ពុជាប្តេជ្ញា៖

- អនុលោមទៅតាមអនុសញ្ញាហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស
- រក្សាសន្តិភាព បន្តកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការបច្ចេកទេស និង
- ច្រានចោលរាល់ការចោទប្រកាន់ណាមួយ ដែលផ្ទុយនឹងបទឈប់បាញ់។

ថ្ងៃសៅរ៍ ១៥កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៥

CMAA

អាសយដ្ឋាន: អគារថ្មី ផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ, ទូរស័ព្ទ: ០២៣ ៨៨៥ ៩៤១, ០២៣ ៥៩២

**KINGDOM OF CAMBODIA**

**Nation Religion King**

**THE ROYAL GOVERNMENT**

**Cambodian Mine Action**
**and Victim Assistance Authority**

File No: √ /CMAA/2025

PRESS RELEASE

CMAA DENIES ALLEGATIONS OF NEW MINE-LAYING AND CALLS FOR FACT-BASED COOPERATION UNDER CEASEFIRE

The Cambodian Mine Action and Victim Assistance Authority (CMAA) strongly refutes the statement issued by the Ministry of Foreign Affairs of Thailand on 9 August 2025, which accused Cambodia of laying new mines.

Cambodia's position is unequivocal: We have not, and will not, plant new landmines. Cambodia is a proud State Party to the Anti-Personnel Mine Ban Convention, which it ratified in 1999, and has an internationally recognized record of removing, not deploying, these indiscriminate weapons. For over three decades, Cambodia has cleared more than one million landmines and nearly three million explosive remnants of war, saving countless lives and restoring land to communities.

At this time, no official and transparent investigation has been carried out regarding the reported incident involving injured Thai soldiers. In the absence of verified facts, it is essential that all parties exercise restraint in public statements. Unsubstantiated accusations not only risk undermining the spirit of cooperation established under the ceasefire but also threaten to erode trust at a moment when constructive engagement is most needed.

Cambodia hopes that the Thai side will respect the points agreed upon at the extraordinary meeting of the Cambodia-Thailand General Border Committee (GBC), especially point two, which states that both sides maintain current troop deployments without further movement, including patrol towards the other side's position.

We reiterate our readiness to work with Thailand, ASEAN partners, and the international mine action community to uphold peace and promote safety.

Cambodia reaffirms:
- Absolute compliance with the Mine Ban Treaty.
- Commitment to peace, dialogue, and technical cooperation.
- Rejection of any action or narrative that undermines the ceasefire.

Phnom Penh, 9 August 2025

CMAA

Address: New Building, St.273, Corner 516, Sangkat Toul Sangker, Khan Russey Keo, Phnom Penh. Tel: 023 885 941, 023 881 492